# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...១១៤..អនុក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការកែសំរួលមាត្រា ៧ ថ្មី ជំពូកទី ៩ ថ្មី នៃអនុក្រឹត្យលេខ ១០០ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៥ និងការច្របាច់បញ្ចូលជំពូកទី ១០ និងទី ១១ នៃអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៦៥ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពី វិសោធនកម្មមាត្រា ៤ មាត្រា ១០ និង មាត្រា ១៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០០ /១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់ មីន និង សង្គ្រោះជនពិការដោយសារមីន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានឃើញអនុក្រឹត្យលេខ ១០០ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីវិសោធនកម្មជំពូកទី ៤ ជំពូកទី ៥ ជំពូកទី ៦ ជំពូកទី ៧ ជំពូកទី ៨ ជំពូកទី ១៣ និងជំពូកទី ១៥ នៃអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- យោងតាមតំរូវការការងារចាំបាច់

## សម្រេច

**មាត្រា មួយ.-**

ត្រូវបានកែសំរួលមាត្រា ៧ ថ្មី ជំពូកទី ៥ ថ្មី នៃអនុក្រឹត្យលេខ ១០០ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៥ និងប្រចាច់បញ្ចូលជំពូកទី ១០ និងទី ១១ នៃអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន ដូចតទៅ :

**មាត្រា ៧.- ថ្មី ពីរ**

៧. អគ្គលេខាធិការដ្ឋាន ត្រូវស្ថិតក្រោមការដឹកនាំគ្រប់គ្រងរបស់អគ្គលេខាធិការ ។ ដើម្បី ធានាឱ្យមានប្រសិទ្ធភាព និងសុក្រឹតភាពការងារខ្ពស់របស់ "អាជ្ញាធរ" អគ្គលេខាធិការដ្ឋានមាននាយកដ្ឋាន ចំនួន ០៥ (ប្រាំ) សំរាប់បំរើការងារតាមមុខងារដូចតទៅ :

៧.១. នាយកដ្ឋានបទប្បញ្ញត្តិ និងត្រួតពិនិត្យ

៧.២ នាយកដ្ឋានផែនការ សេដ្ឋកិច្ចសង្គម និង គ្រប់គ្រងទិន្នន័យ

៧.៣ នាយកដ្ឋានសង្គ្រោះជនពិការដោយសារមីន

៧.៤ នាយកដ្ឋានទំនាក់ទំនងសាធារណៈ

៧.៥ នាយកដ្ឋានរដ្ឋបាលទូទៅ ។

### ជំពូកទី ១០ ថ្មី

**មាត្រា ១៥.-ថ្មី**

នាយកដ្ឋានរដ្ឋបាលទូទៅ ត្រូវទទួលបន្ទុកការងាររដ្ឋបាល បុគ្គលិក ភស្តុភារ និងហិរញ្ញវត្ថុ មាន ភារកិច្ចចំបងដូចតទៅ :

១៥.១. រៀបចំចាត់ចែងភស្តុភារ និងការទិញសំភារៈតាមតម្រូវការចាំបាច់

១៥.២. រៀបចំតាក់តែង និង តាមដានការអនុវត្តបទបញ្ជាផ្ទៃក្នុង និង បទប្បញ្ញត្តិពាក់ព័ន្ធ

១៥.៣. គាំទ្រផ្នែកលិខិតស្នាម និងភស្តុភារ សំរាប់មន្ត្រី និងថ្នាក់ដឹកនាំ "អាជ្ញាធរមីន" បំពេញបេសកកម្ម នៅក្នុង និងក្រៅប្រទេស

១៥.៤. គ្រប់គ្រងរាល់លិខិតបទដ្ឋាន និងឯកសារចេញ-ចូល

១៥.៥. រៀបចំនិងធ្វើការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាតាមលក្ខណៈវិនិច្ឆ័យប្រកបដោយ តម្លាភាព និង អនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិនានារបស់រាជរដ្ឋាភិបាល

១៥.៦. រៀបចំគំរោងថវិកា និង អនុវត្តការប្រើប្រាស់ថវិកា

១៥.៧. តាមដានការអនុវត្តបទប្បញ្ញត្តិហិរញ្ញវត្ថុរបស់ប្រតិបត្តិករសកម្មភាពមីនទាំងអស់

១៥.៨. ចេញចំណាយសាច់ប្រាក់ តាមការបញ្ជារបស់ថ្នាក់ដឹកនាំ "អាជ្ញាធរមីន"

១៥.៩. រៀបចំ និង បញ្ជាក់និយ័តភាពគណនេយ្យប្រចាំឆមាស និង ប្រចាំឆ្នាំ

១៥.១០ធ្វើរបាយការណ៍លំអិតពីចំណូល-ចំណាយ ដោយភ្ជាប់ជាមួយនូវតារាងសមតុល្យរៀងរាល់ខែជូនថ្នាក់ដឹកនាំ "អាជ្ញាធរមីន" ។

**មាត្រា ពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា បី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ សីហា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា បី
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ